| សំបុត្រភស្តុតាង យោធា (ក្រោម 50 U.S.C. § 3931) | លេខសំណុំរឿង | តុលាការជំនុំជម្រះក្តីរដ្ឋ ម៉ាស្សាឈូសែត |
|---|---|---|

| ឈ្មោះករណី<br><br>v. | នាយកដ្ឋានតុលាការ (ជ្រើសរើសយកមួយប៉ុណ្ណោះ)<br>☐ តុលាការក្រុង Boston ☐ តុលាការមូលដ្ឋាន ☐ តុលាការដោះស្រាយវិវាទលំនៅដ្ឋាន<br>☐ តុលាការសម្រាប់អនីតិជន ☐ តុលាការដោះស្រាយទំនាស់ដីធ្លី<br>☐ តុលាការផ្នែកមរតក និងគ្រួសារ ☐ តុលាការជាន់ខ្ពស់<br>ផ្នែកតុលាការ/ខោនធី |
|---|---|

នៅក្រោមច្បាប់ស្តីពីជំនួយស៊ីវិលដល់ទាហាន, 50 U.S.C. § 3931, ខ្ញុំបាទ/នាងខ្ញុំ________________________(បំពេញ**ឈ្មោះ**) បានចុះហត្ថលេខាខាងក្រោម ដែលអះអាងបញ្ជាក់ អស់ពីចំណេះដឹងរបស់ខ្ញុំថា អំណះអំណាងខាងក្រោមគឺពិត៖

1. គិតត្រឹម________________________________________(បំពេញ**ខែ/ថ្ងៃ/ឆ្នាំ**)៖

A. ☐ ភាគីខាងក្រោមកំពុងស្ថិតក្នុង**បរិច្ចារកិច្ចយោធា**ដូចមានចែងក្នុងច្បាប់ស្តីពីជំនួយស៊ីវិលដល់ទាហាន ។

______________________________________________________________________
______________________________________________________________________
______________________________________________________________________

B. ☐ ភាគីខាងក្រោម**មិន**កំពុងស្ថិតក្នុង**បរិច្ចារកិច្ចយោធា**ទេដូចមានចែងក្នុងច្បាប់ស្តីពីជំនួយស៊ីវិលដល់ទាហាន ។

______________________________________________________________________
______________________________________________________________________
______________________________________________________________________

C. ☐ ភាគីខាងក្រោមបាន**បញ្ចប់បរិច្ចារកិច្ចយោធា**ដូចមានចែងក្នុងច្បាប់ស្តីពីជំនួយស៊ីវិលដល់ទាហាន ។ (បញ្ជាក់ផងដែរនូវ**កាលបរិច្ឆេទពិតប្រាកដ**ដែលភាគីបាន**បញ្ចប់**បរិច្ចារកិច្ចយោធា ។)

______________________________________________________________________
______________________________________________________________________
______________________________________________________________________

D. ☐ ខ្ញុំ**មិនអាចកំណត់**ថាតើភាគីខាងក្រោមកំពុងស្ថិតក្នុងបរិច្ចារកិច្ចយោធាដូចមានចែងក្នុងច្បាប់ស្តីពីជំនួយស៊ីវិលដល់ទាហានបានទេ ។ ជាលទ្ធផល ក្រោម 50 U.S.C. § 3931(b)(3) ខ្ញុំយល់ថា តុលាការអាចតម្រូវឲ្យខ្ញុំដាក់សំបុត្រធានាសងប្រាក់ មុនពេលចេញសាលក្រមសម្រេច ។

______________________________________________________________________
______________________________________________________________________
______________________________________________________________________

2. អ្នកត្រូវបាន**តម្រូវ**ឲ្យលើកឡើងនូវអង្គហេតុដែលគាំទ្រដល់សំបុត្រភស្តុតាងនេះ ។ អ្នក**ត្រូវតែ**បំពេញផ្នែកនេះហើយគូសយកជម្រើស “A” ឬ “B” ។

*A.* ☐ ខ្ញុំបានប្រើវេបសាយនៃច្បាប់ស្តីពីជំនួយស៊ីវិលដល់ទាហាន (https://scra.dmdc.osd.mil/) ដើម្បីកំណត់ស្ថានភាពទាហានរបស់ភាគីដែលរាយក្នុងសំបុត្រភស្តុតាងនេះ ។ *(អ្នកត្រូវបាន**តម្រូវ**ឲ្យផ្តល់លទ្ធផលនៃការស្វែងរករបស់អ្នក ។)*

☐លទ្ធផលនៃការប្រើប្រាស់វេបសាយនៃច្បាប់ស្តីពីជំនួយស៊ីវិលដល់ទាហានរបស់ខ្ញុំមានភ្ជាប់មកជាមួយ ។ *(តម្រូវ)*

អង្គហេតុបន្ថែមទៀត *(អាចជ្រើសរើសបានប្រសិនបើមានភ្ជាប់លទ្ធផលស្វែងរកហើយ។)*: ______________________________

______________________________________________________________________

______________________________________________________________________

B. ☐ ខ្ញុំ**មិន**បានប្រើប្រាស់វេបសាយនៃច្បាប់ស្តីពីជំនួយស៊ីវិលដល់ទាហាន (https://scra.dmdc.osd.mil/) ទេ ដើម្បីដើម្បីកំណត់ស្ថានភាពទាហានរបស់ភាគីដែលរាយក្នុងសំបុត្រភស្តុតាងនេះ ។ ប៉ុន្តែអង្គហេតុខាងក្រោមគាំទ្រដល់អំណះអំណាងខាងលើរបស់ខ្ញុំ ចំពោះស្ថានភាពទាហានរបស់ភាគី ។ *(អ្នកត្រូវបាន**តម្រូវ**ឲ្យផ្តល់អង្គហេតុខាងក្រោម ។ សូមបញ្ជាក់ឲ្យច្បាស់លាស់ ។)*

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

**<u>សម្គាល់៖</u>** ពាក្យ “បរិច្ចារកិច្ចយោធា” រាប់បញ្ចូលដូចតទៅនេះ៖ ការចូលបម្រើភារកិច្ចសកម្មជាសមាជិករបស់កងទ័ពជើងគោក ជើងទឹក និងជើងអាកាស ទាហានម៉ារីន ឬឆ្មាំសមុទ្ររបស់សហរដ្ឋអាមេរិក; ការចូលបម្រើជាសមាជិកឆ្មាំជាតិ ដែលស្ថិតក្រោមការកោះហៅឲ្យមកបំពេញភារកិច្ចសកម្មដោយមានការអនុញ្ញាតពីប្រធានាធិបតី ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ សម្រាប់រយៈពេលលើសពី 30 ជាប់គ្នាក្នុងគោលបំណងឆ្លើតបនឹងគ្រាអាសន្នថ្នាក់ជាតិ; ការចូលបម្រើសកម្មជាមន្ត្រីពាក់ស័ក្តិនៃក្រសួងសុខភាពសាធារណៈ ឬរដ្ឋបាលថ្នាក់ជាតិកិច្ចការមហាសមុទ្រ និងបរិយាកាស; និងរយៈពេលណាមួយនៃការចូលបម្រើដែលសមាជិករូបនោះអវត្តមានពីភារកិច្ចដោយមូលហេតុមានជំងឺ របួស ច្បាប់សម្រាក ឬបុព្វហេតុស្របច្បាប់ផ្សេងទៀត ។ ក្រោម 50 U.S.C. § 3911(2) ពលរដ្ឋអាមេរិកណាដែលកំពុងបម្រើកងកម្លាំងរបស់ប្រជាជាតិមួយដែលសហរដ្ឋអាមេរិកមានសម្ព័ន្ធជាមួយក្នុងសង្គ្រាម ឬសកម្មភាពយោធាមួយ ក៏អាចមានសិទ្ធិទទួលបានជំនួយក្រោមច្បាប់ស្តីពីជំនួយស៊ីវិលដល់ទាហាន ប្រសិនបើការចូលបម្រើនោះស្រដៀងគ្នាទៅនឹងនិយមន័យនៃពាក្យ “បរិច្ចារកិច្ចយោធា” ដែលបានពិភាក្សាខាងលើ ។ សូមមើល 50 U.S.C. § 3914។

**បានចុះហត្ថលេខាយល់ព្រម និងបានបញ្ជាក់ ឬប្រកាសថាពិតជាត្រឹមត្រូវ និងហ៊ានទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។**

| | |
|---|---|
| ហត្ថលេខា<br><br>______________________________<br>សរសេរឲ្យច្បាស់ៗ ឬវាយកុំព្យូទ័រនូវឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និងអាសយដ្ឋានអ៊ីមែលរបស់អ្នក | កាលបរិច្ឆេទ<br><br>លេខ BBO (សម្រាប់មេធាវី) |

# តុលាការជំនុំជម្រះក្ដីរដ្ឋ
# ម៉ាស្សាឈូសែត

## <u>ការណែនាំសម្រាប់</u>
## <u>សំបុត្រភស្ដុតាងយោធា (ក្រោម 50 U.S.C. § 3931)</u>

ច្បាប់ស្ដីពីជំនួយស៊ីវិលដល់ទាហាន (SCRA), 50 U.S.C. §§ 3901-4043, គឺជាច្បាប់របស់សហព័ន្ធ ដែលផ្ដល់អត្ថប្រយោជន៍ និងការការពារផ្សេងៗដល់ជនដែលចូលបម្រើយោធា និងអ្នកដែលនៅក្នុងបន្ទុករបស់ពួកគេ ។ ជនទាំងនោះរួមមានសមាជិករបស់កងទ័ពជើងគោក ជើងទឹក និងជើងអាកាស ទាហានម៉ារីន ឬឆ្មាំសមុទ្ររបស់សហរដ្ឋអាមេរិក និងមន្ត្រីពាក់ស័ក្តិនៃក្រសួងសុខភាពសាធារណៈ ឬរដ្ឋបាលថ្នាក់ជាតិកិច្ចការមហាសមុទ្រ និងបរិយាកាស ពេលនៅបម្រើភារកិច្ចសកម្មរបស់ប្រទេសពួកគេ និងមានរយៈពេលរហូតដល់ទៅមួយឆ្នាំក្រោយភារកិច្ចសកម្ម និងសមាជិកឆ្មាំជាតិដែលបំពេញភារកិច្ចមួយចំនួន និងពលរដ្ឋអាមេរិកដែលបម្រើជាមួយកងកម្លាំងយោធាសម្ព័ន្ធមិត្តមួយចំនួន ។

**សំបុត្រភស្ដុតាងយោធា (ក្រោម 50 U.S.C. § 3931)** របស់តុលាការជំនុំជម្រះក្ដីរដ្ឋម៉ាស្សាឈូសែត គឺជាទម្រង់បែបបទតាមបទដ្ឋានដែលប្រើដើម្បីបញ្ជាក់ស្ថានភាពទាហានរបស់ភាគីក្នុងករណីវិវាទមួយ ។ ទម្រង់បែបបទនេះអាចត្រូវបានប្រើក្នុង**គ្រប់ប្រភេទករណី** នៅទីណាដែលការដាក់**សំបុត្រភស្ដុតាងយោធា**មានភាពសមរម្យ ។ ទម្រង់បែបបទនៃសំបុត្រភស្ដុតាងយោធាជាឯកសារទម្រង់ PDF ដែលអាចបំពេញបាន ហើយគោរពតាមក្រមទាំងពីរគឺ 50 U.S.C. § 3931(b) និង Mass. R. Civ. P. 55(b)(4) ។

ឧទាហរណ៍៖ ក្រោមក្រម Mass. R. Civ. P. 55(b)(4) សំបុត្រភស្ដុតាងយោធាត្រូវបានតម្រូវមុនពេលតុលាការចេញសាលក្រមដាច់ណាត់ ។ សាលក្រមដាច់ណាត់ គឺជាសាលក្រមមួយដែលគាំទ្រភាគីមួយ ឬ “ដើមចោទ” ដែលប្ដឹង “ចុងចោទ” ពីបទ “ខកខានក្នុងការឆ្លើយតបគូក្ដី ឬមិនដូច្នោះទេមិនការពារ” ការកាត់សេចក្ដី ។ សូមមើល Mass. R. Civ. P. 55(b)(4) (“គ្មានសាលក្រមដាច់ណាត់ណាត្រូវបានចេញឡើយរហូតទាល់តែមានការដាក់សំបុត្រភស្ដុតាង . . . ដែលចែងពីអង្គហេតុដែលបង្ហាញថាតើចុងចោទកំពុងស្ថិតក្នុងបរិច្ចារកិច្ចយោធាឬអត់ . . .”) ។

សូមវាយកុំព្យូទ័រនូវការឆ្លើយតបរបស់អ្នកនៅលើទម្រង់បែបបទនៃសំបុត្រភស្ដុតាងយោធា ឬប្រើប៊ិចពណ៌ខៀវ ឬខ្មៅ ហើយសរសេរឲ្យច្បាស់ ។

1. សរសេរ ឬវាយកុំព្យូទ័រនូវ “លេខសំណុំរឿង” នៃករណីរបស់អ្នក បើដឹង ។

2. សរសេរ ឬវាយកុំព្យូទ័រនូវ “ឈ្មោះករណី” នៅលើទម្រង់បែបបទ ហើយវាយឈ្មោះភាគីក្នុងករណីវិវាទនេះ៖ ដើមចោទ ចុងចោទ ហើយបើមាន ភាគីដែលចាប់អារម្មណ៍ ឬភាគីចុងបណ្ដឹងឧទ្ធរណ៍ ។

3. គូសធីកយក “នាយកដ្ឋានតុលាការ” ដែលករណីរបស់អ្នកត្រូវបានគេដាក់បណ្ដឹងទៅ ។

4. សរសេរ ឬវាយកុំព្យូទ័រនូវ “ផ្នែកតុលាការ/ខោនធី" សមស្រប ដែលករណីរបស់អ្នកស្ថិតនៅ (ឧ. Brighton Division, តុលាការបណ្ឌុល Attleboro, តុលាការផ្នែកមរតក និងគ្រួសារ Barnstable, ឬខោនធី Barnstable) ។

5. អ្នកត្រូវបានតម្រូវឲ្យបំពេញផ្នែកសំខាន់នៃសំបុត្រភស្ដុតាងនេះ ។ សរសេរ ឬវាយកុំព្យូទ័រនូវឈ្មោះពេញរបស់អ្នក ។ សរសេរ ឬវាយកុំព្យូទ័រនូវកាលបរិច្ឆេទថ្ងៃនេះ ឬកាលបរិច្ឆេទដែលអ្នកបានស្វែងរកស្ថានភាពទាហាននៃភាគីបណ្ដឹង ។

6. សរសេរ ឬវាយកុំព្យូទ័រនូវព័ត៌មានអំពីស្ថានភាពទាហានរបស់ភាគីក្នុងបណ្ដឹង ។ ក្រោមចំណុចទី 1 គូសធីក A, B, C, ឬ D តាមការសមរម្យ ហើយបំពេញព័ត៌មានដែលគេស្នើសុំនៅលើទម្រង់បែបបទសម្រាប់ជម្រើសនីមួយៗ ។ សូមកត់សម្គាល់ថា ប្រសិនបើអ្នកគូសធីកយក D ក្រោម 50 U.S.C. § 3931(b)(3) មុនពេលចេញសាលក្រមសម្រេច តុលាការអាចតម្រូវឲ្យអ្នកដាក់សំបុត្រធានាសងប្រាក់ ពីព្រោះអ្នកបានបញ្ជាក់ថា អ្នកមិនអាចកំណត់ស្ថានភាពទាហានរបស់ភាគីក្នុងបណ្ដឹងបាន ។

7. អ្នកត្រូវបាន**តម្រូវ**ឲ្យបញ្ជាក់ពីអង្គហេតុដែលគាំទ្រសំបុត្រភស្តុតាងយោធា ។ ក្រោមចំណុចទី 2 អ្នក**ត្រូវតែ**បំពេញផ្នែកនេះនៃទម្រង់បែបបទ ហើយគូសយកជម្រើស A ឬ B ។

> **ទាក់ទងនឹងជម្រើស A ៖** អ្នកអាចប្រើវេបសាយនៃច្បាប់ស្ដីពីជំនួយស៊ីវិលដល់ទាហាន (https://scra.dmdc.osd.mil/) ដើម្បីកំណត់ស្ថានភាពទាហានរបស់ភាគីក្នុងបណ្ដឹងដែលអ្នកបានវាយឈ្មោះ ។ ការធ្វើការស្វែងរកតាមអនឡាញតាមរយៈវេបសាយរបស់ SCRA គឺជាវិធីដ៏ងាយបំផុតក្នុងការកំណត់ស្ថានភាពទាហារបស់ភាគីក្នុងបណ្ដឹង ។ ប្រសិនបើអ្នកបានប្រើវេបសាយរបស់ SCRA អ្នកត្រូវបាន**តម្រូវ**ឲ្យផ្ដល់លទ្ធផលស្វែងរករបស់អ្នកមួយច្បាប់ទៅតុលាការ (ជាធម្មតាគឺ វិញ្ញាបនបត្រដែលទាញចេញពីវេបសាយរបស់ SCRA) ។ អ្នកត្រូវតែភ្ជាប់មកជាមួយនូវលទ្ធផលនៃការស្វែងរកទាំងនោះមួយច្បាប់មកជាមួយសំបុត្រភស្តុតាងយោធារបស់អ្នក ។ អ្នកអាចដាក់បញ្ចូលអង្គហេតុបន្ថែម នៅពេលអ្នកផ្ដល់លទ្ធផលនៃការស្វែងរករបស់អ្នកមួយច្បាប់ ។
>
> **ទាក់ទងនឹងជម្រើស B ៖** ប្រសិនបើអ្នកមិនបានប្រើវេបសាយរបស់ SCRA ដើម្បីកំណត់ស្ថានភាពទាហានរបស់ភាគីក្នុងបណ្ដឹងដែលអ្នកបានវាយឈ្មោះទេ អ្នកត្រូវតែផ្ដល់អង្គហេតុជាក់លាក់ដែលគាំទ្រអំណះអំណាងរបស់អ្នក ចំពោះស្ថានភាពទាហានរបស់ភាគីក្នុងបណ្ដឹង ។ ឧទាហរណ៍៖ អ្នកអាចដាក់បញ្ចូលអង្គហេតុដែលអ្នកដឹងតាមរយៈអ្នកក្នុងបញ្ជីទូរស័ព្ទរបស់អ្នក ឬការទំនាក់ទំនងជាមួយភាគីក្នុងបណ្ដឹង។ អ្នកក៏អាចសរសេរទៅកាន់ទីបញ្ជាការយោធាសមស្រប ដែលរាយនៅលើ (http://www.defense.gov/Sites) ដើម្បីកំណត់ស្ថានភាពទាហានរបស់ភាគីក្នុងបណ្ដឹង ។ សូមភ្ជាប់មកជាមួយនូវការឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរដែលអ្នកទទួលបានពីបញ្ជាការយោធាដើម្បីជាការគាំទ្រដល់អំណះអំណាងរបស់អ្នក ។

8. នៅក្រោមពាក្យ "ហត្ថលេខា" និង "កាលបរិច្ឆេទ" ចូរចុះហត្ថលេខា និងដាក់កាលបរិច្ឆេទលើទម្រង់បែបបទនេះ ។ អ្នកអាចចុះហត្ថលេខាលើទម្រង់បែបបទនៃសំបុត្រភស្តុតាងយោធានេះ ជាទម្រង់អេឡិចត្រូនិក ។ សូមឲ្យប្រាកដថាត្រូវសរសេរឲ្យច្បាស់ៗ ឬវាយកុំព្យូទ័រនូវឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និងអាសយដ្ឋានអ៊ីមែលរបស់អ្នក នៅពីក្រោមហត្ថលេខារបស់អ្នក ។ មេធាវីរដ្ឋ ម៉ាស្សាឈូសែត ត្រូវបានតម្រូវឲ្យផ្ដល់នូវលេខក្រុមប្រឹក្សាត្រួតពិនិត្យវិជ្ជាជីវៈមេធាវី (BBO) ។ មេធាវីដែលទទួលបានអាជ្ញាប័ណ្ណក្នុងដែនយុត្តាធិការផ្សេង ត្រូវតែផ្ដល់លេខវិជ្ជាជីវៈមេធាវីតាមរដ្ឋរបស់ពួកគេ ។